## ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៨ សសរ

# សេចក្ដីសំរេច

## ស្ដីពី

ការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្ដឹង
តវ៉ារបស់ប្រជាពលរដ្ឋនៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង

---

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្ដី ពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី .
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ .
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សំរេច

**ប្រការ១** : បង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដើម្បីចុះពិនិត្យស្រាវជ្រាវបណ្ដឹងតវ៉ារបស់ប្រជាពលរដ្ឋចំនួន ១១២គ្រួសារនៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ដែលមានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- តំណាងក្រសួងមហាផ្ទៃ | ប្រធាន |
| ២- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- តំណាងក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | សមាជិក |
| ៤- តំណាងក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ | សមាជិក |

៥- តំណាងអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ សមាជិក

៦- តំណាងអភិបាលខេត្តបាត់ដំបង សមាជិក

៧- តំណាងយោធភូមិភាគ៥ សមាជិក

ប្រការ២ : គណៈកម្មការនេះមានភារកិច្ចសហការជាមួយអាជ្ញាធរដែនដីគ្រប់ថ្នាក់ដែលពាក់ព័ន្ធ ចុះពិនិត្យស្រាវជ្រាវ និង សរុបសំរួលបណ្តឹងតវ៉ារបស់ប្រជាពលរដ្ឋ ចំនួន ១១២គ្រួសារ នៅភូមិតានី ឃុំល្វា ស្រុកបវេល ខេត្តបាត់ដំបង ដែលពាក់ព័ន្ធនឹងដីធ្លី ចំនួន ៣៦០ហិកតា និង ព្រមទាំងខិតខំប្រមែប្រមូលឯកសារ សំខាន់ៗ និងពត៌មានពិតជាក់ស្តែង ដើម្បីរាយការណ៍ជូនរាជរដ្ឋាភិបាលពិនិត្យ និង សំរេច ។

ប្រការ៣ : សមាជិកទាំងអស់របស់គណៈកម្មការត្រូវចូលរួមប្រជុំ និង ចុះបំពេញភារកិច្ចតាមការអញ្ជើញរបស់ប្រធាន ។

ប្រការ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រី រដ្ឋមន្ត្រីបណ្តាក្រសួង ប្រធានស្ថាប័នដែលពាក់ព័ន្ធ ព្រមទាំងសមាសភាពក្រសួងមានចែងក្នុងប្រការ១ មានភារកិច្ចទទួលអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ វិច្ឆិកា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចអគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
( ដើម្បីជូន និងចុះផ្សាយជ្រាប )
- ដូចប្រការ ១ និង ៤
" ដើម្បីអនុវត្ត "
- ឯកសារ- កាលប្បវត្តិ